# គម្រោងរេដបូកដែនជម្រកសត្វព្រៃកែវសីមា

# ២០២០ -២០២១

KSWS REDD+

VERIFICATION DRAFT

  

រៀបចំដោយ៖ អង្គការសមាគមអភិរក្សសត្វព្រៃ (WCS). Version 1.5

ឯកសារនេះជាការសង្ខេបអំពីលទ្ធផលនៃការអនុវត្តគម្រោងរេដបូកនៅដែនជម្រកសត្វព្រៃកែវសីមា ពីឆ្នាំ២០២០ ដល់ ២០២១។ ឯកសារលម្អិតអំពីគម្រោង និងផលប្រយោជន៍នានាកន្លងមក មាននៅក្នុងរបាយការណ៍តាមដានការអនុវត្តគម្រោង។ របាយការណ៍តាមដានការអនុវត្តគម្រោង និងឯកសារផ្សេងៗទៀតអាចរកបានតាមរយៈ៖

- ស្នើសុំពីបុគ្គលិកគម្រោងរេដបូកកែវសីមាដោយផ្ទាល់
- ចុះឈ្មោះដើម្បីទាញយកឯកសារពីគេហទំព័រ របស់អង្គការ Verra តាមរយៈតំណរភ្ជាប់៖ https://registry.verra.org/app/projectDetail/VCS/1650
- ចុះឈ្មោះដើម្បីទាញយកឯកសារពីគេហទំព័ររបស់អង្គការ WCS កម្ពុជាតាមរយៈតំណរភ្ជាប់៖ https://cambodia.wcs.org/About-Us/Publications.aspx
- ស្នើសុំពីអាជ្ញាធរមូលដ្ឋាន តាមភូមិដែលចូលរួមអនុវត្តគម្រោងរេដបូកផ្តល់ជូននៅក្នុងកិច្ចពិភាក្សាពិគ្រោះយោបល់សាធារណៈ

របាយការណ៍តាមដានវឌ្ឍនភាពអាចទាញយកបានដោយស្កេន QR កូដ៖

**ម្ចាស់គម្រោង៖ រាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងបរិស្ថាន**
ទំនាក់ទំនង៖ ឯកឧត្តម បណ្ឌិត ជួប ប៉ារីស៍ អនុរដ្ឋលេខាធិការ នៃក្រសួងបរិស្ថាន
អាស័យដ្ឋាន៖ អគារមរតកតេជោ ដីឡូត៍លេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
អ៊ីម៉ែល៖ paris.ncgg@gmail.com

**ដៃគូការងារបច្ចេកទេស៖ អង្គការសមាគមអភិរក្សសត្វព្រៃ (WCS)**
អាស័យដ្ឋាន៖ ផ្ទះលេខ ២១ ផ្លូវលេខ ២១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ WCS PO Box 1620

PRE-VERIFICATION DRAFT

# សេចក្តីសង្ខេប

## ការអនុវត្តគម្រោង

- មានការចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងក្នុងឆ្នាំ២០២០-២០២១ គ្រប់គោលបំណងសំខាន់ៗ ដូចជា៖
  - **គោលបំណងទី១៖** ឯកសារផែនការ និងឯកសារច្បាប់ដែលគាំទ្រដល់ការកំណត់តំបន់ប្រើប្រាស់ដីក្នុងតំបន់ការពារធម្មជាតិ និងការវាស់វែងដីសមូហភាពជនជាតិដើមភាគតិច ផែនការវិនិយោគឃុំ ត្រូវបានអនុម័ត និងអនុវត្ត
  - **គោលបំណងទី២៖** ការកាត់បន្ថយបទល្មើសព្រៃឈើ និងសត្វព្រៃ តាមរយៈការពង្រឹងការអនុវត្តច្បាប់ជាប្រចាំ ការដោះស្រាយវិវាទដីធ្លី និងការចុះល្បាតព្រៃតាមសហគមន៍
  - **គោលបំណងទី៣៖** គាំទ្រដល់ការប្រើប្រាស់ដី និងធនធានធម្មជាតិប្រកបដោយនិរន្តរភាព រួមមានការងារចាក់វ៉ាក់សាំងបសុសត្វ សម្របសម្រួលការចុះបញ្ជីដីសមូហភាព ជនជាតិដើមភាគតិច និងសម្របសម្រួលរៀបចំសហគមន៍តំបន់ការពារធម្មជាតិ និងកម្មវិធីកាត់បន្ថយការប្រើប្រាស់អុស
  - **គោលបំណងទី៤៖** ការលើកកម្ពស់ជីវភាពរស់នៅ និងការយល់ដឹងពីការងារអភិរក្ស តាមរយៈការគាំទ្រដល់ទេសចរណ៍ធម្មជាតិ ការកាត់បន្ថយជម្លោះរវាងមនុស្ស និងសត្វព្រៃ កម្មវិធីការពារសំបុកបក្សីដែលជាប្រភេទសត្វកម្រ ការប្រមូលកំទេចអន្ទាក់សត្វព្រៃ ការពង្រីកការងារបង្កបង្កើនផលស្រូវមិត្តភាពសត្វព្រៃ និងការបែងចែកផលប្រយោជន៍ដល់សហគមន៍ដោយផ្ទាល់នៃប្រាក់ចំណូលពីការលក់ឥណទានកាបូន។
  - **គោលបំណងទី៥៖** ទិន្នន័យការងារតាមដានត្រួតពិនិត្យត្រូវបានផ្តល់ជូនដល់រាជរដ្ឋាភិបាលសម្រាប់ធ្វើការសម្រេចចិត្តនានា រួមមានទិន្នន័យ ត្រួតពិនិត្យគម្របព្រៃឈើ ចំនួនប្រភេទសត្វព្រៃសំខាន់ៗ និងរបាយរបស់វា និងកម្មវិធីស្រាវជ្រាវជាមួយដៃគូជាតិ និងអន្តរជាតិ
  - **គោលបំណងទី៦៖** ប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល តាមរយៈការងារគ្រប់គ្រងដែលមានភាពបត់បែន ការបណ្តុះបណ្តាល និងវាយតម្លៃស្នាដៃការងាររបស់បុគ្គលិក ការកែលម្អដំណើរការហិរញ្ញវត្ថុ និងការគ្រប់គ្រងសម្ភារៈ ឧបករណ៍
  - **គោលបំណងទី៧៖** ជួយគាំទ្រដល់សុវត្ថិភាពផ្នែកហិរញ្ញវត្ថុ សង្គម និងនយោបាយ តាមរយៈការអនុវត្តកម្មវិធីនានាដែលផ្តល់មូលនិធិដោយម្ចាស់ជំនួយ និងការរួមចំណែកដល់កម្មវិធីរេដបូកថ្នាក់ជាតិ

PRE-VERIFICATION DRAFT

## ផលប្រយោជន៍ចំពោះអាកាសធាតុ

- ចាប់តាំងពីឆ្នាំ២០១០ មក គម្រោងបានបញ្ចៀសការបាត់បង់ព្រៃឈើសរុបចំនួន ២៥.២០៤ ហិកតានៅក្នុងតំបន់អនុវត្តគម្រោងរេដបូក ហើយបានបញ្ចៀសការបាត់បង់ព្រៃឈើបានចំនួន ៦.០៤៣ ហិកតានៅក្នុងរយៈពេលត្រួតពិនិត្យគម្រោង (២០២០-២០២១)។
- តាមរយៈទិន្នន័យមានន័យថាបានកាត់បន្ថយការបំភាយឧស្ម័នកាបូនិចចំនួន២១.១៧១.៥៧៨ $tCO_2e$ក្នុងរយៈពេល១២ឆ្នាំហើយបានកាត់បន្ថយការបំភាយឧស្ម័នកាបូនិចចំនួន ៤.៧៨៤.៥៦៦ $tCO_2e$ ក្នុងរយៈពេលត្រួតពិនិត្យនេះ (២០២០-២០២១)។
- ព្រៃឈើចំនួន ៤.៣២៧ ហិកតា ត្រូវបានបាត់បង់នៅក្នុងតំបន់អនុវត្តគម្រោងនៅក្នុងរយៈពេលត្រួតពិនិត្យនេះ។ ទោះបីទំហំនៃការបាត់បង់នេះតិចជាងកម្រិតមូលដ្ឋានដែលបានព្យាករណ៍សម្រាប់សេណារីយ៉ូដែលមិនមានគម្រោងក៏ដោយ ក៏ចាំបាច់ត្រូវពង្រឹងការអនុវត្តបន្ថែមទៀតដើម្បីកាត់បន្ថយបញ្ហាទំហំនៃការបាត់បង់ព្រៃឈើឱ្យបានជាអប្បបរិមា ។

## ផលប្រយោជន៍ចំពោះសហគមន៍

- គម្រោងរេដបូកបានជួយធ្វើឱ្យ សុខុមាលភាព និងជីវភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋចំនួន ២២.០៥១នាក់នៅក្នុងតំបន់គោលដៅរបស់គម្រោងមានភាពប្រសើរឡើង
- គម្រោងបានជួយបង្កើនប្រាក់ចំណូលដោយផ្ទាល់ ឬដោយប្រយោលដល់ប្រជាពលរដ្ឋចំនួន ១១.៧៩៩ នាក់។
- គម្រោងបានបង្កើនលទ្ធភាពទទួលទឹកស្អាតប្រើប្រាស់សម្រាប់ប្រជាពលរដ្ឋចំនួន២.២៦៨នាក់ តាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធ
- គម្រោងបានជួយសម្របសម្រួល និងពង្រឹងសមត្ថភាពសហគមន៍លើការគ្រប់គ្រងដីសមូហភាពជនជាតិដើមភាគតិចដែលមានកម្មសិទ្ធចំនួនប្រាំពីរភូមិ និងសហគមន៍ដែលកំពុងស្ថិតក្នុងដំណើរការចុះបញ្ជីប្រាំបីភូមិ
- គម្រោងបានជួយសម្របសម្រួលពង្រឹងសមត្ថភាពគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិចំនួនពីរដែលបានទទួលស្គាល់ជាផ្លូវការពីក្រសួងបរិស្ថាន និងបន្តសម្របសម្រួលរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិចំនួនបួនសហគមន៍
- គម្រោងបានចែករំលែកថវិកាចំនួន ២00.000 ដុល្លាអាមេរិក ដែលជាចំណូលទទួលបានពីការលក់ឥណទានកាបូន ដល់ភូមិចំនួន ២០ ដែលចូលរួមអនុវត្តគម្រោងរេដបូកតាមរយៈយន្តការបែងចែកផលប្រយោជន៍ ។ មកទល់ពេលបច្ចុប្បន្ន ការចែករំលែកថវិកាសរុបដល់សហគមន៍ទាំងនេះ មាន ចំនួន ៤៣៨.៥៥៤ ដុល្លាអាមេរិកហើយ។
- សហគមន៍បានប្រើប្រាស់មូលនិធិដែលទទួលបានពីការបែងចែកផលប្រយោជន៍ នេះសម្រាប់ការងារអាទិភាពក្នុងកិច្ចការអភិវឌ្ឍន៍សហគមន៍ រួមមានដូចជាៈ ការល្បាតសហគមន៍តំបន់

PRE-VERIFICATION DRAFT

ការពារធម្មជាតិ និងដីសម្បូរភាពជនជាតិដើមភាគតិច ការរៀបចំទឹកប្រើប្រាស់ គ្លីនិកសុខភាពចល័ត ពង្រឹងការអប់រំ និងការបង្កើតប្រាក់ចំណូល។

## ផលប្រយោជន៍ចំពោះជីវចម្រុះ

- គម្រោងទទួលផលប្រយោជន៍ល្អក្នុងកិច្ចការអភិរក្សជីវចម្រុះ ធៀបនឹងសេណារីយ៉ូមូលដ្ឋាន
- លទ្ធផលនៃការស្រាវជ្រាវ តាមដានសត្វព្រៃប្រភេទជិតផុតពូជបំផុត និងប្រភេទជិតផុតពូជបានបង្ហាញថាមានស្ថិរភាព (ដូចជាស្វាកន្ទុយស ទោចថ្គាល់លឿង និងសត្វព្រៃមួយចំនួនទៀត)
- ចំនួនពពួក គោសាទិសប្រើស និងជ្រូកព្រៃ បង្ហាញពីរបាយណ៍ថយចុះគួរឱ្យព្រួយបារម្ភ ដែលត្រូវបានគេសង្កេតឃើញទូទាំងប្រទេសកម្ពុជា និងបានព្យាករណ៍នៅក្នុងសេណារីយ៉ូមូលដ្ឋាន
- ត្រូវចាត់វិធានការបន្ទាន់ដើម្បីដោះស្រាយការធ្លាក់ចុះទាំងនេះនៅទូទាំងប្រទេស និងនៅក្នុងតំបន់ ដែនជម្រកសត្វព្រៃកែវសីមា

សកម្មភាពសំខាន់ៗមួយចំនួនរបស់គម្រោងមាននៅក្នុងឧបសម្ព័ន្ធ ១ ។

PRE-VERIFICATION DRAFT

# សេចក្តីសង្ខេបអំពីគម្រោង

ដែនជម្រកសត្វព្រៃកែវសីមា មានទីតាំងស្ថិតនៅក្នុងខេត្តមណ្ឌលគិរី និងខេត្តក្រចេះ ភាគខាងកើតនៃប្រទេសកម្ពុជា ជាទីតាំងមួយដ៏សំខាន់សម្រាប់ជីវចម្រុះរបស់ជាតិ តំបន់ និងសកលលោក ហើយក៏ជាជម្រកតាំងពីបុរាណកាល រហូតមកដល់បច្ចុប្បន្នរបស់ជនជាតិដើមភាគតិចព្នងផងដែរ ។

ដែនជម្រកសត្វព្រៃកែវសីមា មានវត្តមានសត្វព្រៃជាង ១.០០០ ប្រភេទត្រូវបានកត់ត្រា ហើយតំបន់នេះគឺជាដែនជម្រកដ៏ធំជាងគេបំផុតនៅលើពិភពលោកសម្រាប់ប្រភេទសត្វជាច្រើន រួមមានស្វាកន្ទុយស ទោចថ្ពាល់លឿង និងជាជម្រកសម្រាប់ប្រភេទសត្វជាច្រើនទៀតដែលមាននៅក្នុងប្រទេស តំបន់ និងសកលលោក ។ សត្វព្រៃដែលរងការគំរាមកំហែងជាសកលជាង ៨៥ ប្រភេទ ឃើញមានវត្តមាននៅក្នុងតំបន់នេះ រួមទាំងសត្វព្រៃដែលជិតផុតពូជបំផុតចំនួន ១៣ ប្រភេទ ហើយដែលត្រូវបានចាត់ចំណាត់ថ្នាក់ខ្ពស់បំផុតនៅក្នុងបញ្ជីក្រហម នៃប្រភេទជិតផុតពូជរបស់អង្គការ IUCN ផងដែរ។

តំបន់នេះជាជម្រករបស់ប្រជាពលរដ្ឋជាង ២០.០០០ នាក់ រួមទាំងជនជាតិដើមភាគតិចព្នងប្រហែល ១២.៥០០ នាក់ដែលមានទំនាក់ទំនងវប្បធម៌ ជំនឿ និងធនធានផ្សាភ្ជាប់ទៅនឹងព្រៃឈើក្នុងដែនជម្រកសត្វព្រៃកែវសីមានេះ។

អាកាសធាតុមានខ្យល់មូសុងត្រូពិច ដោយមានភ្លៀងធ្លាក់ពី ២.២០០ ទៅ ២.៨០០ មីលីម៉ែត្រក្នុងមួយឆ្នាំ នៅទីស្នាក់ការកណ្តាលក្នុងស្រុកកែវសីមា ភាគច្រើនចាប់ពីខែឧសភា ដល់ខែតុលា ។ រយៈកម្ពស់នៃតំបន់ការពារធម្មជាតិមានចាប់ពី ៦០-៧៥០ ម៉ែត្រពីលើនីវ៉ូទឹកសមុទ្រ។

តំបន់នេះបានបង្កើតជាតំបន់អភិរក្សជីវចម្រុះសីមានៅក្នុងឆ្នាំ២០០២ ក្រោយមកបានប្រែក្លាយជាព្រៃការពារសីមា ហើយនៅឆ្នាំ២០១៦ បានក្លាយជា ដែនជម្រកសត្វព្រៃកែវសីមាគ្របដណ្តប់លើផ្ទៃដី ២៩២.៦៩០ ហិកតា ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។ ចក្ខុវិស័យសម្រាប់តំបន់នេះគឺ "ជាតំបន់ទេសភាពព្រៃឈើដែលត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពដើម្បីធ្វើឲ្យមានការកើនឡើងចំនួនសត្វព្រៃ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍" ។ ចក្ខុវិស័យនេះអាចទទួលបានភាពជោគជ័យ តាមរយៈការគ្រប់គ្រង ការការពារប្រកបដោយប្រសិទ្ធភាព មានការចូលរួមពីភាគីពាក់ព័ន្ធក្នុងមូលដ្ឋាន និងកម្មវិធីនានាដើម្បីរក្សាស្ថិរភាពនៃការប្រើប្រាស់ដីធ្លី ។

ទោះបីជាដែនជម្រកសត្វព្រៃកែវសីមាស្ថិតក្រោមការការពារ និងគ្រប់គ្រងក៏ដោយ ក៏តំបន់នេះស្ថិតនៅក្រោមការគំរាមកំហែងពីកត្តាមួយចំនួនដូចជា ការពង្រីកកសិកម្មក្នុងទ្រង់ទ្រាយធំ/តូច ការជួញដូរព្រៃឈើ និងការបរបាញ់សត្វព្រៃខុសច្បាប់ ការប្រើប្រាស់ដីដែលគ្មាននិរន្តរភាព និងការកាប់ឆ្ការ

PRE-VERIFICATION DRAFT

ព្រៃយកដី។ ការបាត់បង់ព្រៃឈើ និង ទីជម្រកសត្វព្រៃ បានធ្វើឱ្យមានផលប៉ះពាល់ដល់ការប្រែប្រួលអាកាសធាតុ បាត់បង់ជីវចម្រុះ និងបាត់បង់ធនធានធម្មជាតិដែលជាទីអាស្រ័យក្នុងការប្រកបរបរចិញ្ចឹមជីវិតបែបប្រពៃណីរបស់ជនជាតិដើមភាគតិច។

ដើម្បីទទួលបានជោគជ័យនូវចក្ខុវិស័យក្នុងការគ្រប់គ្រប់តំបន់ការពារធម្មជាតិឱ្យបានល្អ គម្រោងរេដបូក បានផ្តួចផ្តើម នៅក្នុងឆ្នាំ២០១០ ដែលគ្របដណ្តប់លើតំបន់ស្នូលដែនជម្រកសត្វព្រៃកែវសីមា ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រជាសហគមន៍ចំនួន២០ភូមិ។ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងបរិស្ថានជាសេនាធិការ ក្រោមកិច្ចគាំទ្រផ្នែកបច្ចេកទេស និងការអនុវត្តគម្រោង ដោយអង្គការសមាគមអភិរក្សសត្វព្រៃ (WCS) គម្រោងនេះត្រូវបានវាយតម្លៃផ្តល់សុពលភាពជាផ្លូវការក្នុងឆ្នាំ២០១៤ ហើយឆ្លងកាត់ការត្រួតពិនិត្យផ្ទៀងផ្ទាត់តាមកាលកំណត់ ដែលរួមមានសវនកម្មឯករាជ្យក្នុងការវាយតម្លៃការអនុវត្តគម្រោង និងការត្រួតពិនិត្យគម្រោងផងដែរ ។

ឯកសារសង្ខេបនេះគឺជារបាយការណ៍អនុវត្តគម្រោងរេដបូកដែនជម្រកសត្វព្រៃកែវសីមាក្នុងឆ្នាំ ២០២០-២០២១សម្រាប់ការផ្ទៀងផ្ទាត់លើកទី៤។ ឯកសាររបាយការណ៍សម្រាប់ការការផ្ទៀងផ្ទាត់ពីមុនកន្លងមកអាចទាញយកបានពីគេហទំព័រដែលបានផ្តល់ជូនខាងលើ។ ក្នុងអំឡុងពេលនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ទាំងនេះ ការបាត់បង់ព្រៃឈើជាក់ស្តែង ត្រូវបានប្រៀបធៀបទៅនឹងទិន្នន័យមូលដ្ឋានដែលជាការព្យាករណ៍សម្រាប់សេណារីយ៉ូដែលមិនមានការគាំទ្រពីគម្រោងរេដបូក។ ការគណនាទិន្នន័យកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិច គឺត្រូវយកទិន្នន័យការបញ្ចៀសការបាត់បង់ព្រៃឈើទៅធៀបជាមួយទិន្នន័យមូលដ្ឋាននេះ។ បន្ទាប់ពីរកឃើញទិន្នន័យកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិច ហើយទើបអាចគណនារកតម្លៃឥណទានកាបូនបាន។ ឥណទានកាបូនទាំងនេះត្រូវបានលក់ទៅឱ្យបុគ្គល និងក្រុមហ៊ុនដែលចង់ទូទាត់សងវិញនូវការបំភាយកាបូនផ្ទាល់ខ្លួនរបស់ពួកគេ ហើយមូលនិធិដែលបានមកពីការលក់ទាំងនេះយកទៅប្រើប្រាស់ដើម្បីការពារដែនជម្រកសត្វព្រៃកែវសីមា និងគាំទ្រដល់ការអភិវឌ្ឍសហគមន៍មូលដ្ឋានប្រកបដោយចីរភាព ។

PRE-VERIFICATION DRAFT

*តារាងទី ១៖ អង្គភាពរដ្ឋបាលដែលពាក់ព័ន្ធក្នុងការអនុវត្តគម្រោង*

| ខេត្ត | ស្រុក | ឃុំ | ភូមិសំខាន់ | ភូមិអ្នកប្រើប្រាស់ដទៃទៀត |
|---|---|---|---|---|
| មណ្ឌលគិរី | កែវសីមា | ស្រែខ្ទុម | អូរអាម អូររណារ ស្រែល្វី | |
| | | ស្រែព្រះ | ស្រែព្រះ ហ្គាទី ពូចារ អូច្រារ ពូគង់ | |
| | | ស្រែឈូក | ចក់ចារ ខ្មុម ស្រែអណ្ដោល ស្រែខ្ទង់ | |
| | | មេម៉ង់ | ពូកេះ ពូង៉ោល | |
| | អូររាំង | សែនមនោរម្យ | អណ្ដូងក្រឡឹង ពូហ្រាម ពូរ៉ាង | |
| | សែនមនោរម្យ | រមនា | | ស្រែ អ៊ី ពូត្រុំ ពូតាំង |

ION DRAFT




*រូបភាពទី១៖ ភូមិគោលដៅ ក្នុងដែនជម្រកសត្វព្រៃកែវសីមា តំបន់ស្នូលត្រូវបានបន្លិច*

## ការអនុវត្តគម្រោង

ដែនជម្រកសត្វព្រៃកែវសីមា គឺជាគម្រោងដ៏ធំហើយមានភាពស្មុគស្មាញ ដោយមានការអនុវត្តសកម្មភាពជាច្រើនឆ្ពោះទៅសម្រេចបាននូវគោលដៅសំខាន់ៗចំនួន៤៖

១. រក្សានូវភាពចម្រុះនៃប្រភេទព្រៃឈើនៅក្នុងតំបន់

២. បង្កើននូវចំនួនប្រភេទសត្វព្រៃ ដែលត្រូវការអភិរក្ស

៣. បង្កើននូវសុវត្ថិភាព និងផលិតភាពនៃធនធានធម្មជាតិ ដើម្បីគាំទ្រដល់ជីវភាពរបស់សហគមន៍មូលដ្ឋាន

៤. មានដីស្រែចំការគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ដល់ជីវភាពរបស់សហគមន៍មូលដ្ឋាន

សកម្មភាពដែលត្រូវអនុវត្តគឺផ្អែកទៅលើគោលបំណងចំនួន៧ ហើយសកម្មភាពជាឧទាហរណ៍មួយចំនួនដែលបានអនុវត្តក្នុងអំឡុងពេលនេះ មានដូចខាងក្រោមនេះ។ បញ្ជីសកម្មភាពទាំងអស់ដែលបានអនុវត្តក្នុងអំឡុងពេលតាមដាននេះមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ១ ។

- **គោលបំណងទី១៖ ឯកសារផែនការ និងឯកសារច្បាប់សម្រាប់តំបន់ដែនជម្រកសត្វព្រៃកែវសីមា និងទីតាំងជុំវិញបានអនុម័ត និងអនុវត្តព្រមទាំងមានការយល់ដឹងដោយសហគមន៍មូលដ្ឋាន បុគ្គលិកអង្គការWCS មន្ត្រីរាជរដ្ឋាភិបាល វិស័យឯកជន។**
  - បានវាស់វែងព្រំប្រទល់ដែនជម្រកសត្វព្រៃកែវសីមា ដីសមូហភាពជនជាតិដើមភាគតិច និងសហគមន៍តំបន់ការពារធម្មជាតិ
  - ព័ត៌មានអំពីដែនជម្រកសត្វព្រៃកែវសីមា និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិត្រូវបានយល់ដឹងផ្សព្វផ្សាយ តាមរយៈយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយ និងផ្ទាំងប៉ាណូនានា
  - បានចូលរួមចំណែកក្នុងផែនការវិនិយោគឃុំសម្រាប់ភូមិដែលចូលរួមក្នុងគម្រោងរេដបូកដែនជម្រកសត្វព្រៃកែវសីមា
  - បានជួយគាំទ្រដល់ការងារកំណត់តំបន់គ្រប់គ្រង និងដំណើរការរៀបចំផែនការគ្រប់គ្រង
  - បានចូលរួមក្នុងដំណើរការរៀបចំផែនទីសុរិយោដីសម្រាប់ខេត្តមណ្ឌលគិរី និងស្រុកមួយចំនួន

- **គោលបំណងទី ២៖ ការកាត់បន្ថយបទល្មើសសត្វព្រៃ និងព្រៃឈើ តាមរយៈការអនុវត្តច្បាប់ដោយផ្ទាល់**
  - បានគាំទ្រដល់ការអនុវត្តច្បាប់ រួមមានទាំងការកសាងសមត្ថភាព និងបច្ចេកទេស ការគ្រប់គ្រងសម្ភារៈ និងថវិកា
  - បានចុះល្បាតជាង ៦.៥០០លើក មានការរឹបអូសសម្ភារៈខុសច្បាប់ចំនួន ១.៣០០ មុខ ឃាត់ខ្លួនជនល្មើសចំនួន ៨៥ ករណី និងធ្វើការព្រមានជាលាយលក្ខណ៍អក្សរចំនួន ១៦៧ ករណី។
  - សំណុំរឿងចំនួន២០ ករណីពាក់ព័ន្ធនឹងបទល្មើសធនធានធម្មជាតិ ត្រូវបានបញ្ជូនទៅតុលាការខេត្ត

PRE-VERIFICATION DRAFT

- ទទួលបានជោគជ័យក្នុងការដោះស្រាយវិវាទដីធ្លី រួមទាំងសាលដីកាស្ថាពររបស់តុលាការខេត្តបដិសេធការទាមទារដីឯកជន និងការស្ម័គ្រចិត្តសងត្រឡប់មកវិញនូវដីដែលបានកាន់កាប់ដោយខុសច្បាប់បន្ទាប់ពីការសម្របសម្រួលរបស់គម្រោងរួចមក ។
- បានសម្របសម្រួលការបង្កើតក្រុមល្បាតសហគមន៍ចំនួន ១៧ភូមិ ដោយប្រតិបត្តិការក្រោមកិច្ចព្រមព្រៀង ជាមួយប្រធានការិយាល័យដែនជម្រកសត្វព្រៃកែវសីមា

- **គោលបំណងទី៣៖ ការប្រើប្រាស់ដីធ្លី និងធនធានដោយប្រជាសហគមន៍មូលដ្ឋានប្រកបដោយចីរភាព**
  - គម្រោងបានចាប់ផ្តើមកម្មវិធីចាក់វ៉ាក់សាំងការពារសត្វគោក្នុងស្រុក ប្រឆាំងនឹងជំងឺដុំពកលើស្បែក ក្រោមកិច្ចសហប្រតិបត្តិការជាមួយអង្គការ WWF និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តមណ្ឌលគិរី ។
  - ដីសម្បហាភាពជនជាតិដើមភាគតិចក្នុងភូមិចំនួន៦បានទទួលការអនុម័តបឋមពីក្រសួងបរិស្ថាន និងក្រសួងរៀបចំដែនដី និងនគរូបនីយកម្ម
  - បានជួយគាំទ្រក្រសួងអភិវឌ្ឍន៍ជនបទក្នុងការអនុវត្តបំពេញនិតិវិធីចុះបញ្ជីដីសម្បហាភាពជនជាតិដើមភាគតិច
  - បានជួយគាំទ្រដល់ការគ្រប់គ្រងដីសម្បហាភាពជនជាតិដើមភាគតិចដែលបានទទួលប័ណ្ណកម្មសិទ្ធដូចជាការកំណត់ព្រំប្រទល់ និងការលើកផ្លាកសញ្ញា ការគាំទ្រផ្នែកច្បាប់ដើម្បីដោះស្រាយបញ្ហាជម្លោះដីធ្លី ដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការថ្មី ការកសាងសមត្ថភាព ការធ្វើបច្ចុប្បន្នភាពបញ្ជីសមាជិក (គ្រួសារថ្មីដែលមានបំណងចូលជាសមាជិកសហគមន៍) និងសម្របសម្រួលការទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិចដោយអាជ្ញាធរឃុំចំនួន៥ ភូមិ
  - បានសម្របសម្រួលរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិចំនួន២ ទទួលស្គាល់ជាផ្លូវការពីក្រសួងបរិស្ថាន និងកំពុងបន្តគាំទ្ររៀបចំបង្កើតនៅសហគមន៍មួយចំនួនទៀត
  - បានចែកចាយចង្ក្រាន សន្សំសំចៃអុស ជូនប្រជាពលរដ្ឋចំនួន ៥៩២គ្រួសារ ។

- **គោលបំណងទី ៤៖ សកម្មភាពគាំទ្រលើការលើកកម្ពស់ជីវភាពរស់នៅ និងផ្តល់ការយល់ដឹងអំពីការងារអភិរក្ស ដល់ប្រជាជនមានភាពសកម្ម**
  - បានគាំទ្រដល់គម្រោងអេកូទេសចរណ៍ធំៗចំនួនពីរដែលដំណើរការដោយអង្គការជាដៃគូ (ជំរំទោចចាហ៊ូ (Jahoo Camp) គាំទ្រដោយដោយអង្គការក្តីសង្ឃឹមពិភពលោកអន្តរជាតិ (WHI) និងគម្រោងអភិរក្សដំរី (Elephant Valley) ដោយអង្គការ Elephant Livelihoods Initiative Environment(E.L.I.E) រួមមានទាំងការផ្តល់មូលនិធិទប់ទល់នឹងផលប៉ះពាល់ពីវិបត្តិជម្ងឺកូវីដ-១៩
  - បានអនុវត្តកម្មវិធីការពារសំបុកសត្វត្រយ៉ងយក្ស និងសត្វត្រដក់តូច

PRE-VERIFICATION DRAFT

- ក្រុមដោះស្រាយជម្លោះរវាងមនុស្ស-សត្វព្រៃបានឆ្លើយតបទៅនឹងរបាយការណ៍ចំនួន៦៥ករណី ពីប្រជាសហគមន៍ចំនួន១១ភូមិ។
- អន្ទាក់ជាច្រើនត្រូវបានដោះដោយក្រុមការងារទទួលបន្ទុកដោះអន្ទាក់របស់អង្គការ WCS ក្រុមល្បាតសហគមន៍ និងដោយក្រុមការងារអនុវត្តច្បាប់
- បានគាំទ្រដល់ការបង្កើនជីវភាព តាមរយៈសិប្បកម្មកែច្នៃផលិតផលឫស្សី ស្រូវមិត្តភាពសត្វព្រៃ (IBIS Rice) ការផ្សារភ្ជាប់ទីផ្សារអនុផលព្រៃឈើ និងកម្មវិធីផ្តល់ជំនួយផ្នែកកសិកម្មផ្សេងៗទៀត
- ពេលនេះមានកសិករជាង ៥០ គ្រួសារ និងផ្ទៃដីជាង ៣០០ ហិកតា ត្រូវបានអនុវត្តក្រោមកម្មវិធីស្រូវមិត្តភាពសត្វត្រយ៉ង
- ចំណូលពីការលក់ឥណទានកាបូន បានបែងចែកដល់ភូមិគោលដៅរេដបូកចំនួន២០ សរុបជាទឹកប្រាក់ចំនួន ២០០.០០០ ដុល្លាអាមេរិកក្នុងរយៈពេលនៃរបាយការណ៍នេះ
- បានគាំទ្រដល់សហគមន៍ក្នុងការគ្រប់គ្រងមូលធិនិរេដបូកដើម្បីអនុវត្តសកម្មភាពអភិវឌ្ឍសហគមន៍
- បានរៀបចំប្រព័ន្ធបង់ថ្លៃដោយផ្អែកលើការអនុវត្តសម្រាប់ការគណនាមូលនិធិសម្រាប់ផ្តល់ឱ្យភូមិនីមួយៗនៅពេលក្រោយ

- **គោលបំណងទី ៥៖ ព័ត៌មានស្តីអំពីការប្រែប្រួលសង្គម និងអេកូសាស្ត្ររយៈពេលវែងត្រូវបានប្រមូលដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងតំបន់ការពារ**
  - បន្តតាមដានគម្របព្រៃឈើ និងការបាត់បង់ព្រៃឈើ
  - កម្មវិធីតាមដានត្រួតពិនិត្យជីវចម្រុះកាលពីឆ្នាំ២០២០ បានបញ្ចប់ការងារត្រួតពិនិត្យតាមខ្សែបន្ទាត់ត្រង់សិកបានធ្វើរបាយការណ៍ប៉ាន់ប្រមាណចំនួនសត្វព្រៃក្នុងរយៈពេល១០ឆ្នាំ ចាប់ពីឆ្នាំ ២០១០ ដល់២០២០ ព្រមទាំងបានបំពាក់ម៉ាស៊ីនថតសត្វស្វ័យប្រវត្តិផងដែរ
  - ក្រុមតាមដានត្រួតពិនិត្យសត្វព្រៃនៅដែនជម្រកសត្វព្រៃកែវសីមាទទួលបានការទទួលស្គាល់ស្នាដៃពីក្រសួងបរិស្ថានក្នុងកិច្ចការអភិរក្សនៅដែនជម្រកសត្វព្រៃកែវសីមា ចាប់តាំងពីឆ្នាំ២០១០
  - បានបង្កើតនូវភាពជាដៃគូជាមួយកម្មវិធីស្រាវជ្រាវអន្តរជាតិ និងសាកលវិទ្យាល័យជាតិនានា
- **គោលបំណងទី ៦៖ មានយន្តការ គ្រប់គ្រងរដ្ឋបាល គណនេយ្យ និងភស្តុភារប្រកបដោយប្រសិទ្ធភាព**
  - បានផ្តល់កម្មវិធីបណ្តុះបណ្តាលជាង ២៥វគ្គ ដល់បុគ្គលិកគម្រោង ដូចជាការយល់ដឹងអំពីយេនឌ័រ ការអភិវឌ្ឍន៍ប្រកបដោយបរិយាប័ន្ន ការស្រាវជ្រាវត្រួតពិនិត្យសត្វព្រៃតាមខ្សែបន្ទាត់ត្រង់សិក ការសម្របសម្រួលការតស៊ូមតិសហគមន៍ សិទ្ធិមនុស្ស អភិបាលកិច្ចដីធ្លី និងការបញ្ជាក់ផលិតផលកសិកម្មសរីរាង្គ
  - បន្តប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទ្រព្យឧបករណ៍ សម្ភារៈ ធានាការប្រើប្រាស់ធនធានសម្ភារៈប្រកបដោយប្រសិទ្ធភាព

PRE-VERIFICATION DRAFT

- បន្តការគ្រប់គ្រងដោយមានភាពបត់បែន រួមមានកិច្ចប្រជុំប្រចាំខែជាមួយភាគីអ្នកពាក់ព័ន្ធនឹងគម្រោង ដូចជាមន្ទីរបរិស្ថានជាដើម។
- **គោលបំណងទី៧៖ ដែនជម្រកសត្វព្រៃកែវសីមាមានសុវត្ថិភាពផ្នែកហិរញ្ញវត្ថុ សង្គម និងនយោបាយសម្រាប់រយៈពេលយូរអង្វែង**
  - បានបន្តការអនុវត្តគម្រោងអភិរក្សដែនជម្រកសត្វព្រៃកែវសីមាក្រោមទីភ្នាក់ងារជំនួយ USAID គម្រោង CAMPAS គម្រោង Conservation de la biodiversité et croissance verte dans le hotspot Indo-Birman project ក្រោមមូលនិធិ AFD និងគម្រោង USFWS ក្រោមមូលនិធិ Endangered Species Asian Elephant Conservation Fund។
  - បានជួយគាំទ្រដល់ការអភិវឌ្ឍន៍កម្មវិធីរេដបូកថ្នាក់ជាតិ
  - បន្តដំណើរការអនុវត្តគម្រោងរេដបូកនៅក្នុងដែនជម្រកសត្វព្រៃកែវសីមា។

ទាំងនេះជាសកម្មភាពជ្រើសរើសមួយចំនួនក្នុងចំណោមសកម្មភាពជាច្រើនដែលបានអនុវត្តដោយគម្រោងរេដបូក ។ សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមមើលឧបសម្ព័ន្ធ១ និងរបាយការណ៍ពេញលេញអំពីការងារតាមដានត្រួតពិនិត្យ ។

PRE-VERIFICATION DRAFT

## ផលប្រយោជន៍នៃគម្រោង

- រូបភាពថតដោយផ្កាយរណបដែលមានគុណភាពខ្ពស់ពី Landsat និង Sentinel 2A ត្រូវបានប្រើដើម្បីកំណត់តំបន់បាត់បង់ព្រៃឈើ នៅក្នុងតំបន់គម្រោង និងតំបន់ទ្រនាប់។ ព័ត៌មានលម្អិតនៃការវិភាគមាននៅក្នុងរបាយការណ៍តាមដានត្រួតពិនិត្យ។
- បើមិនមានគម្រោងរេដបូកដែនជម្រសត្វព្រៃកែវសីមាទេ ព្រៃឈើទំហំ ៣៨.៦៧៤ហិកតា ត្រូវបានព្យាករណ៍នឹងបាត់បង់នៅក្នុងតំបន់ស្នូលគម្រោងរេដបូក ក្នុងរយៈពេល១២ឆ្នាំ ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០២១ ហើយនៅក្នុងរយៈពេលត្រួតពិនិត្យនេះ ព្រៃឈើទំហំ ១០.៣៧០ហិកតា ត្រូវបានព្យាករណ៍ថានឹងត្រូវបាត់បង់។ ការបាត់បង់ព្រៃឈើដែលបានព្យាករណ៍នេះត្រូវបានបង្ហាញក្នុង រូបភាពទី២ (ពណ៌ទឹកក្រូច) ។
- ផ្អែកលើរូបភាពថតជាក់ស្តែងពីផ្កាយរណប ទំហំពិតនៃការបាត់បង់ព្រៃឈើនៅក្នុងតំបន់ស្នូលងពីឆ្នាំ២០១០ ដល់ឆ្នាំ២០២១ មានទំហំ ១១.០៤២ហិកតា (ដូចបានបង្ហាញជាពណ៌ក្រហមក្នុងរូបភាពទី២) មានកម្រិតទាបជាងបើធៀបទៅនឹងទំហំដែលបានព្យាករណ៍ ហើយនៅក្នុងរយៈពេលត្រួតពិនិត្យនេះ ព្រៃឈើទំហំ ៤.៣២៧ហិកតា ត្រូវបានបាត់បង់នៅក្នុងតំបន់ស្នូល ។




*រូបភាពទី២៖ ការព្យាករណ៍អំពីសេណារីយ៉ូនៃការបាត់បង់ព្រៃឈើមិនមានគម្រោង (ពណ៌ទឹកក្រូច) និងការបាត់បង់ព្រៃឈើជាក់ស្តែង (ពណ៌ក្រហម) នៅក្នុងដែនជម្រកសត្វព្រៃកែវសីមាពីឆ្នាំ២០១០ ដល់ឆ្នាំ២០២១ (តំបន់ស្នូលត្រូវបានបន្លិច)*

- ចាប់តាំងពីឆ្នាំ២០១០ មក គម្រោងបានទប់ស្កាត់ការបាត់បង់ព្រៃឈើសរុបចំនួន ២៥.២០៤ ហិកតា នៅក្នុងតំបន់អនុវត្តគម្រោងរេដបូក ហើយបានទប់ស្កាត់ការបាត់បង់ព្រៃឈើបានចំនួន ៦.០៤៣ ហិកតានៅក្នុងរយៈពេលត្រួតពិនិត្យគម្រោង។
- តាមរយៈទិន្នន័យមានន័យថាការកាត់បន្ថយការបំភាយឧស្ម័នកាបូនិចមានចំនួន ២១.១៧១.៥៧៨ $tCO_2e$ ក្នុងរយៈពេល ១២ឆ្នាំ ហើយកាត់បន្ថយការបំភាយឧស្ម័នកាបូនិចចំនួន ៤.៧៨៤.៥៦៦ $tCO_2e$ ក្នុងរយៈពេលត្រួតពិនិត្យនេះ។

## ចំពោះសហគមន៍

ប្រសិនបើមិនមានការអនុវត្តគម្រោងរេដបូកនៅដែនជម្រកសត្វព្រៃកែវសីមា ទេ ការព្យាករណ៍សេណារីយ៉ូសហគមន៍ក្នុងតំបន់សហគមន៍មានលទ្ធផលដូចខាងក្រោម៖

- ប្រាក់ចំណូលជាមធ្យមរបស់សហគមន៍ភាគច្រើនអាចនឹងមានការកើនឡើង ប៉ុន្តែក្រុមមួយចំនួនអាចនឹងមានការថយចុះដោយសារតែមានការកើនឡើងការប្រើប្រាស់ធនធានធម្មជាតិដោយពុំមាននិរន្តរភាព (ដូចវល្លិ៍ ឈើ ឫស្សី គ្រាប់ស្លែង ត្រី និងសត្វព្រៃជាដើម។ល។) ហើយប្រាក់ចំណូលដែលបានមកពីធនធានធម្មជាតិនឹងធ្លាក់ចុះនាពេលអនាគត។ ការព្យាករណ៍នេះនឹងក្លាយជាការពិតសម្រាប់ប្រជាជនខ្មែរ និងជនជាតិដើមភាគតិច ហើយវាកាន់តែធ្ងន់ធ្ងរជាងនេះទៅទៀតដោយសារតែមានតម្រូវការកាន់តែខ្លាំងលើការប្រើប្រាស់ធនធានធម្មជាតិ ។
- ការផ្គត់ផ្គង់ទឹក និងគុណភាពទឹកមានការថយចុះដោយសារការបាត់បង់ព្រៃឈើ និងការពង្រីកសកម្មភាពកសិកម្ម ឬការរុករករ៉ែនៅក្នុងតំបន់គម្រោងដែលនៅភាគខាងលើប្រភពទឹក។
- ប្រជាកសិករមួយចំនួននឹងទទួលបានអត្ថប្រយោជន៍ពីការពង្រីកការកាន់កាប់ដីរបស់ពួកគេ ប៉ុន្តែមនុស្សជាច្រើនផ្សេងទៀត ជាពិសេសគ្រួសារជនជាតិដើមភាគតិចដែលខ្សត់ខ្សោយ អាចជួបប្រទះនឹងការបាត់បង់ដី និងប្រាក់ចំណូល ឬអនុផលនានាសម្រាប់ចិញ្ចឹមជីវិត ដែលធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះ និងមានអសន្តិសុខស្បៀងកាន់តែខ្លាំង។ គ្រួសារបងប្អូនជនជាតិខ្មែរជាច្រើនអាចជួបប្រទះនឹងអសន្តិសុខកាន់តែខ្លាំងដោយសារការកាន់កាប់ដីដែលទន្ទ្រានយកដោយខុសច្បាប់ ហើយគ្រួសារទាំងអស់ប្រឈមនឹងហានិភ័យខ្ពស់ពីការរឹបអូសដីធ្លីរបស់ពួកគេ និងជម្លោះនានាដែលបណ្តាលមកពីបញ្ហាដីសម្បទាន។
- ដីនៅតំបន់ជាច្រើននឹងបាត់បង់ជីជាតិដោយសារតែទម្លាប់កសិកម្មដែលពុំមានចីរភាព ហើយវាកាន់តែលំបាកជាងនេះទៅទៀតប្រសិនបើការកាន់កាប់ដីនោះពុំមានសុវត្ថិភាពទេនោះ។
- សហគមន៍ជនជាតិដើមភាគតិចអាចប្រឈមនឹងការលំបាកក្នុងជីវភាពរស់នៅ ដោយសារតែមានការធ្លាក់ចុះនូវការអនុវត្តទំនៀមទម្លាប់ វប្បធម៌ បាត់បង់សិទ្ធិក្នុងការចេញចូលដីព្រៃអារក្ស ហើយអាចនឹងមានការផ្លាស់ប្តូរពីការធ្វើស្រែចំការ ទៅជាកម្មករស៊ីឈ្នួលដោយកម្លាំង។

PRE-VERIFICATION DRAFT

- កម្រិតអក្ខរភាពក្នុងចំណោមមនុស្សពេញវ័យនឹងបន្តស្ថិតក្នុងកម្រិតទាបដដែលដោយសារតែកង្វះការអប់រំក្រៅប្រពន្ធ័។

ផ្ទុយពីសេណារីយ៉ូជាមូលដ្ឋាននេះ មានកត្តាជាច្រើនដែលត្រូវបានព្យាករណ៍ថានឹងមានភាពប្រសើរឡើងវិញដោយសារតែវត្តមាននៃគម្រោងរេដបូកនៅក្នុងតំបន់ដែនជម្រកសត្វព្រៃកែវសីមា។ ការព្យាករណ៍ទាំងនេះមានបង្ហាញនៅក្នុងតារាងទី២ខាងក្រោមជាមួយដោយភស្តុតាងជាក់ស្តែងមួយចំនួនដែលគម្រោងបានអនុវត្តនៅក្នុងកំឡុងពេលនៃរបាយការណ៍ត្រួតពិនិត្យនេះ។ ព័ត៌មានលម្អិតបន្ថែមទៀតអំពីការអនុវត្តគម្រោង មាននៅក្នុងឧបសម្ព័ន្ធ ១ ។

ផលប៉ះពាល់នានាត្រូវបានតាមដានត្រួតពិនិត្យតាមយន្តការរបស់គម្រោងដោយផ្អែកលើសូចនាករជាង៣០ ហើយការសិក្សាវាយតម្លៃអំពីផលប៉ះពាល់សង្គមក៏ត្រូវបានធ្វើឡើងជាផ្លូវការរៀងរាល់៥ឆ្នាំម្តងផងដែរ ។ ការសិក្សាវាយតម្លៃអំពីផលប៉ះពាល់សង្គមលើកក្រោយនឹងប្រព្រឹត្តិទៅក្នុងឆ្នាំ២០២២នេះ។

*តារាងទី ២. ការព្យាករណ៍អំពីលទ្ធផលនានានៃគម្រោង រេដបូក នៅក្នុងដែនជម្រកសត្វព្រៃកែវសីមា ដែលបានធ្វើកាលមុនពេលចាប់ផ្តើមគម្រោង និងសកម្មភាពនានាដែលគម្រោងបានអនុវត្តនៅក្នុងអំឡុងពេលនៃការត្រួតពិនិត្យនេះ*

| **ផលប្រយោជន៍ដែលបានព្យាករណ៍** | **សកម្មភាពជាក់ស្តែងមួយចំនួនដែលគម្រោងបានអនុវត្តក្នុងកំឡុងពេលនៃការត្រួតពិនិត្យនេះ** |
|---|---|
| លើកកម្ពស់សុខុមាលភាពប្រជាសហគមន៍គ្រប់ស្រទាប់វណ្ណៈ រួមទាំងជនដែលងាយរងគ្រោះដែលបណ្តាលមកពីការបាត់បង់ធនធានធម្មជាតិផងដែរ | បុគ្គលិកគម្រោង បានធ្វើការដើម្បីធានាថាសហគមន៍មានសិទ្ធស្របច្បាប់ ក្នុងការប្រើប្រាស់ធនធានធម្មជាតិ តាមរយៈ ការគ្រប់គ្រងដីសម្ហូហភាពជនជាតិដើមភាគតិច ឬសហគមន៍តំបន់ការពារធម្មជាតិ ។ គណកម្មការសហគមន៍ដីសម្ហូហភាពជនជាតិដើមភាគតិចភូមិ អណ្តូងក្រឡឹង បានសម្រេចបែងចែកចំណូល ពីអេកូទេសចរណ៍ទៅជួយដល់សមាជិកសហគមន៍ដែលជាជនចាស់ជរា និងងាយរងគ្រោះ ជួយពង្រឹងអំណាចរបស់ប្រជាសហគមន៍ដើម្បីទប់ស្កាត់ការបាត់បង់ធនធានធម្មជាតិ តាមរយៈការចុះល្បាតព្រៃ(ពង្រឹងការអនុវត្តច្បាប់) ការបញ្ចូលសមាជិកភាពរបស់តំណាងសហគមន៍ទៅក្នុងបណ្តាញអ្នកប្រើប្រាស់អនុផលព្រៃឈើក្នុងកម្រិតជាតិ និងអន្តរជាតិ ព្រមទាំងបានជួយបណ្តុះបណ្តាល និងផ្តល់ការគាំទ្រនានាផងដែរ ។ |
| បានកាត់បន្ថយជាអប្បរិមានូវការធ្លាក់ចុះនៃសន្តិសុខ និង | គាំទ្រដល់ការងារស្តារព្រៃឈើឡើងវិញនូវតំបន់ព្រៃរិចរិលដែលស្ថិតក្រោមការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិ ។ ការបណ្តុះពូជឫស្សីដែលមានក្នុងសហគមន៍ស្រាប់នៅតាមសួនបណ្តុះកូនឈើសហគមន៍សម្រាប់ |

PRE-VERIFICATION DRAFT

| | |
|---|---|
| លទ្ធភាពបន្តពូជនៃធនធានធម្មជាតិ ហើយនៅកន្លែងខ្លះទៀតថែមទាំងអាចធ្វើឲ្យមានការកើនឡើងវិញផងដែរ | យកទៅដាំឡើងវិញនៅតាមព្រៃ។ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពត្រូវបានបញ្ចូលទៅក្នុងផែនការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិដែលទើបបង្កើតថ្មី។ ការចែកចង្ក្រានមិត្តភាពបរិស្ថានដើម្បីជួយកាត់បន្ថយតម្រូវការអុស។ ការគាំទ្រផ្នែកច្បាប់ដោយឯករាជ្យដល់គណកម្មការសហគមន៍ដីសមូហភាពជនជាតិដើមភាគតិចដើម្បីចូលរួមការពារដីពីអ្នកខាងក្រៅសហគមន៍។ |
| ទប់ស្កាត់ ឬកាត់បន្ថយជាអប្បបរិមានូវការធ្លាក់ចុះនៃគុណភាព និងប្រភពទឹក | ផលប្រយោជន៍ដែលទទួលបានពីការបែងចែកចំណូលក្រោមគម្រោង រេដបូកត្រូវបានយកទៅប្រើប្រាស់ដើម្បីខួងអណ្តូងស្នប់ និងតម្លើងប្រព័ន្ធចែកចាយទឹកស្អាតកម្រិតតូច-មធ្យម ដើម្បីលើកស្ទួយលទ្ធភាពទទួលបានទឹកស្អាតប្រើបរិភោគ។ បានសាងសង់បង្គន់អនាម័យដើម្បីកាត់បន្ថយការបន្ទោរបង់ពាសវាលពាសកាល និងធ្វើឱ្យស្ត្រីមានសុវត្ថិភាពជាងមុន។ ជួយបណ្តុះបណ្តាលកសិករអំពីបច្ចេកទេសធ្វើស្រែដោយកាត់បន្ថយការប្រើប្រាស់ប្រព័ន្ធស្រោចស្រព |
| បញ្ហាបាត់បង់ដីធ្លីរបស់ប្រជាសហគមន៍ក្រីក្រមានកម្រិតទាប និងនៅថេរ | គាំទ្រដល់គណៈកម្មាធិការសហគមន៍ដីសមូហភាពជនជាតិដើមភាគតិច ដើម្បី គ្រប់គ្រងការប្រើប្រាស់ដីបម្រុងសម្រាប់កសិកម្ម រួមទាំងការដោះស្រាយសំណើពីប្រជាជនដែលពុំមែនជាសមាជិកសហគមន៍ដែលមានបំណងចូលមករស់នៅក្នុងតំបន់។ គាំទ្រក្រសួងបរិស្ថានក្នុងការកំណត់អត្តសញ្ញាណទីតាំងដីផ្សេងទៀតដែលប្រជាជនមានបំណងចូលមករស់នៅដោយខុសច្បាប់ក្នុងតំបន់សហគមន៍ការពារធម្មជាតិ។ |
| ផលិតភាពកសិកម្ម និងនិរន្តរភាពកើនឡើង | កសិករក្នុងភូមិចំនួនបីទទួលបានការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មដែលជួយឱ្យដីកាន់តែមានជីជាតិ ប្រើប្រាស់ទឹកតិច និងអនុវត្តតាមគោលការណ៍សរីរាង្គ។ |
| ការខាតបង់ដោយសារ បញ្ហាដីសម្បទានត្រូវបានកាត់បន្ថយជាអប្បបរិមា /ត្រូវបានបញ្ឈប់ | គាំទ្រប្រជាសហគមន៍នៅភូមិ ពូញ៉ាវ ឱ្យចូលរួមពិភាក្សាជាមួយម្ចាស់សម្បទានដែលទទួលបានការអនុញ្ញាតិឱ្យមានការអភិវឌ្ឍទេសចរណ៍ឯកជននៅក្បែរដីសហគមន៍ |

PRE-VERIFICATION DRAFT

| | |
|---|---|
| ការរំលោភបំពានយកដី និងការទន្ទ្រានយកដីដោយខុសច្បាប់ត្រូវបានកាត់បន្ថយជាអប្បបរិមា ឬត្រូវបានបញ្ឈប់ | ទទួលបានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល នានា លើការពង្រឹងការអប់រំអំពីសិទ្ធិដីធ្លី ការចុះបញ្ជីដីធ្លី និងការស្វែងរកឬ រាយការណ៍អំពីការកាន់កាប់ដីធ្លីខុសច្បាប់។ ការគាំទ្រជាបន្តបន្ទាប់ដល់គណៈកម្មាការសហគមន៍ដីសមូហភាពជនជាតិដើមភាគតិច ក្នុងអំឡុងពេលវាស់វែងដីរដ្ឋ និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីជូនប្រជាពលរដ្ឋនៅដែនជម្រកសត្វព្រៃកែវសីមា ដើម្បីធានាថាដំណើរការនេះនឹងមិនប៉ះពាល់ដល់ដីសមូហភាពជនជាតិដើមភាគតិច ។ ផ្តល់ការគាំទ្រផ្នែកច្បាប់ដល់គណៈកម្មាការដីសមូហភាពជនជាតិដើមភាគតិចដើម្បីមានលទ្ធភាពការពារដីពីការឈ្លានពានរបស់អ្នកមកពីខាងក្រៅ។ |
| ស្ថាប័នជាប្រពៃណី និងស្ថាប័នសហគមន៍ដែលបង្កើតថ្មីធ្វើការមានប្រសិទ្ធភាព | បង្ហាត់បង្រៀនគណៈកម្មាការសហគមន៍ ដើម្បីឱ្យគណកម្មាការអាចដឹកនាំកិច្ចប្រជុំបានដោយខ្លួនឯង។ សាលប្រជុំសហគមន៍ត្រូវបានសាងសង់ឡើងដោយប្រើប្រាស់ថវិកាដែលបានទទួលពីការបែងចែកផលប្រយោជន៍គម្រោងរេដបូក។ គម្រោងព្យាយាមសម្របសម្រួលប្រើប្រាស់ការគ្រប់គ្រងសហគមន៍តាមបែបប្រពៃណី(ចាស់ទុំ)ដែលមានពីមុនមកដោយស្របតាមស្ថានភាពជាក់ស្តែង ។ |
| រឹតចំណងទាក់ទងផ្នែកវប្បធម៌ឲ្យកាន់តែស្អិតរមួត | មូលនិធិដែលបានពីចាហ្វ៊ (មូលនិធិសត្វទោច)បានប្រើប្រាស់ដើម្បីរៀបចំកម្មវិធីប្រពៃណីវប្បធម៌របស់សហគមន៍នានាតាមរយៈការចុះល្បាតព្រៃរបស់សហគមន៍ធ្វើឲ្យសមាជិកសហគមន៍មានសិទ្ធិអំណាចក្នុងការចូលរួម ការពារធនធានធម្មជាតិរបស់ពួកគេ។ ការតាំងពិព័រណ៍តាមភូមិបានជួយលើកកម្ពស់ការយល់ដឹងអំពីការងារអភិរក្សព្រៃឈើ។ ការបង្កើតក្រុមសន្សំប្រាក់សហគមន៍ដើម្បីជួយឲ្យសមាជិកសហគមន៍ទាំងអស់សម្រេចតាមគោលដៅរបស់ខ្លួន ។ |
| បង្កើនអក្ខរកម្មក្នុងចំណោមមនុស្សពេញវ័យ | សហគមន៍ដែលចូលរួមទាំងអស់ទទួលបានការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ។ អាគារសិក្សាត្រូវបានជួសជុល ។ បានចែកចាយសម្ភារៈសិក្សាដល់សិស្សានុសិស្សក្រីក្រ ។ យុទ្ធនាការចុះឈ្មោះចូលរៀន និងការផ្តល់អាហារពេលព្រឹកដល់សិស្សដែលគាំទ្រដោយថវិកាបានមកពីការបែងចែកផលប្រយោជន៍ក្រោមគម្រោងរេដបូកសុទ្ធតែបានជួយលើកកម្ពស់អក្ខរភាពរបស់យុវជនតាំងពីក្មេងវ័យ ។ |

PRE-VERIFICATION DRAFT

| | |
|---|---|
| បង្កើនជម្រើសក្នុងការប្រកបរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព | គាំទ្រដល់ការប្រមូលផលឫស្សីប្រកបដោយនិរន្តរភាព និងការបណ្តុះបណ្តាលរបៀបធ្វើសិប្បកម្មឫស្សី រួមទាំងការផ្តល់ឧបករណ៍សម្រាប់កែច្នៃដើម្បីបង្កើនតម្លៃបន្ថែមផងដែរ។ អេកូទេសចរណ៍បានផ្តល់ការងារដល់ប្រជាសហគមន៍មូលដ្ឋាន។ ផ្តល់ការងារជាអ្នកការពារសំបុកសត្វស្លាបដែលជិតផុតពូជ និងជាអ្នកថែទាំដំរី។ អង្ករមិត្តភាពសត្វព្រៃត្រូវបានលក់ក្នុងតម្លៃថ្លៃជាងតម្លៃទីផ្សារ។ |

## ផលប្រយោជន៍ដោយផ្ទាល់ពីការបែងចែកមូលនិធិកាបូន

- បន្ថែមពីលើសកម្មភាពគម្រោងដែលផ្តល់អត្ថប្រយោជន៍ដល់សហគមន៍ដូចបានរៀបរាប់ខាងលើ គម្រោងនេះបានបែងចែកមូលនិធិពីការលក់ឥណទានកាបូនទៅសហគមន៍ចំនួន២០ភូមិ ដោយផ្ទាល់ក្រោមគម្រោងរេដបូក នៅក្នុងដែនជម្រកសត្វព្រៃកែវសីមា។ បន្ទាប់មកសហគមន៍ក្នុងភូមិនីមួយៗជាអ្នកកំណត់អាទិភាពសកម្មភាពអភិវឌ្ឍនៅក្នុងភូមិរបស់ពួកគាត់ដោយផ្ទាល់។
- ការបែកចែកមូលធិនិកាបូនទៅសហគមន៍លើកដំបូងត្រូវបានធ្វើឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ សរុបជាទឹកប្រាក់ចំនួន ២៣៨.៥៥៤ ដុល្លារអាមេរិក។ មូលនិធិនេះភាគច្រើនត្រូវបានប្រើប្រាស់សម្រាប់ការកែលម្អលទ្ធភាពទទួលបានទឹកស្អាត ដែលជាអាទិភាពដ៏សំខាន់នៅកន្លែងជាច្រើន។
- ការបែកចែកមូលធិនិកាបោនទៅសហគមន៍ លើកទីពីរត្រូវបានធ្វើឡើងក្នុងខែមិថុនា ឆ្នាំ២០២១ សរុបជាទឹកប្រាក់ចំនួន ២០០.០០០ដុល្លារអាមេរិក។
- ការទូទាត់បន្ទាប់នឹងផ្តេកលើការអនុវត្តដោយប្រើសូចនាករ រួមមានលើការការពារព្រៃឈើ ការចូលរួមក្នុងការងារអភិរក្ស និងការអភិវឌ្ឍន៍សហគមន៍ក្នុងកំឡុងឆ្នាំ២០២១ ។ ការបែកចែកមូលធិនិកាបូនទៅសហគមន៍ នៅដំណាក់កាលបន្ទាប់ គ្រោងធ្វើឡើងនៅត្រឹមចុងត្រីមាសទី២ ឆ្នាំ២០២២ ។
- រហូតមកដល់ពេលនេះ មានគម្រោងនៅតាមសហគមន៍ចំនួនជាង១២៧ ត្រូវបានគាំទ្រដោយមូលនិធិទាំងនេះ រួមមានការការពារព្រៃឈើ ការចុះល្បាតដីសមូហភាពជនជាតិដើមភាគតិច សហគមន៍តំបន់ការពារធម្មជាតិ ការកសាងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ទឹកស្អាត គ្លីនិកសុខភាពចល័ត កែលម្អការអប់រំ និងការបង្កើតប្រាក់ចំណូល។

## ជីវចម្រុះ

- ដែនជម្រកសត្វព្រៃកែវសីមាបានបង្កើតឡើងក្នុងគោលបំណងសំខាន់ៗចំនួនបី ដែលក្នុងនោះគោលបំណងទី១ គឺដើម្បី «ការពារ និងថែរក្សាទីជម្រកសត្វព្រៃ និងប្រព័ន្ធអេកូឡូស៊ី ក៏ដូចជាបំពេញលក្ខខណ្ឌចាំបាច់នានាសម្រាប់ប្រភេទសត្វព្រៃ រុក្ខជាតិ និងជីវៈចម្រុះគ្រប់ប្រភេទ»។

PRE VERIFICATION DRAFT

- ប្រសិទ្ធភាពនៃការងារអភិរក្ស និងលទ្ធផលឆ្ពោះទៅសម្រេចបានគោលដៅនេះអាចវាស់វែងបាន តាមរយៈគោលបំណងរបស់គម្រោង និងតាមរយៈការអង្កេតតាមដានវត្តមានជីវៈចម្រុះ។ របាយការណ៍នេះបង្ហាញនូវទិដ្ឋភាពមួយផ្នែកនៃកម្មវិធីអង្កេតតាមដានសត្វព្រៃដែលផ្តោតទៅលើចំនួន និងរបាយណ៍សត្វព្រៃចំនួន១៣ប្រភេទសំខាន់ៗដែលមានវត្តមាននៅក្នុងដែនជម្រកសត្វព្រៃកែវសីមា។
- ចំនួនសត្វពានរ៦ប្រភេទដែលកំពុងសិក្សាតាមដានមានស្ថានភាពប្រសើរឡើង។ ចំនួនសត្វពានរចំនួន ៣ ប្រភេទ (មានស្វាកន្ទុយស ទោចថ្កាល់លឿង និងស្វាក្តាម)នៅថេរ ហើយចំនួនពានរមួយប្រភេទទៀត គឺស្វាត្រោសកំពុងមានការកើនឡើង។ ការរក្សាបានចំនួនពួកពានរដែលជិតផុតពូជឱ្យនៅមានចំនួនថេរគឺជាជោគជ័យដ៏ធំធេងរបស់ការងារអភិរក្ស។ ប៉ុន្តែចំនួនពពួកពានរពីរប្រភេទគឺ (ស្វាអង្កត់ និងស្វាព្រាម) នៅក្នុងដែនជម្រកសត្វព្រៃកែវសីមាកំពុងធ្លាក់ចុះ។
- យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថាចំនួនសត្វក្ងោកនៅក្នុងដែនជម្រកសត្វព្រៃកែវសីមា មានការកើនឡើង ដែលប្រការនេះបញ្ជាក់ពីភាពជោគជ័យដ៏ធំមួយសម្រាប់ការអភិរក្សសត្វប្រភេទនេះ នៅក្នុងដែនជម្រកសត្វព្រៃកែវសីមា ទោះបីជាចំនួនប្រភេទសត្វនេះមានការថយចុះជាច្រើននៅទូទាំងពិភពលោកក្តី។
- យោងតាមការសិក្សាស្រាវជ្រាវបានបង្ហាញឱ្យដឹងថា ចំនួននៃពពួកថនិកសត្វដែលមានក្រចកជើងជំពាមស្ថិតក្នុងស្ថានភាពគួរឱ្យព្រួយបារម្ភណ៍។ ចំនួនពពួកថនិកសត្វដែលមានក្រចកជើងជំពាមចំនួន៦ដែលមានវត្តមាននៅដែនជម្រកសត្វព្រៃកែវសីមាមានការថយចុះ។ ប្រភេទសត្វឈ្លូស ត្រូវបានចាត់ទុកជាប្រភេទដែលប្រឈមនឹងការបរបាញ់ ហើយចំនួនរបស់វាមានការថយចុះ៥០ភាគរយ ក្នុងចន្លោះពីឆ្នាំ ២០១៤ ដល់២០២០។ ដោយឡែកចាប់ពីឆ្នាំ ២០១០មកដង់ស៊ីតេនៃប្រភេទសត្វរមាំង និងសត្វប្រើសគឺមានចំនួនទាបបំផុតនៅលើបន្ទាត់ស្រាវជ្រាវត្រង់សិក។ ក៏ដូចគ្នាដែរដង់ស៊ីតេនៃប្រភេទសត្វទន្សោង និងសត្វខ្ទីង គឺមានចំនួនទាបបំផុតដែលទៅអនាគតអាចនឹងមិនអាចគណនាចំនួនរបស់វាបានឡើយ។ សរុបសេចក្តីមកពពួកថនិកសត្វក្រចកជំពាមមាឌធំចំនួន៤ប្រភេទនេះគឺមានការថយចុះក្នុងដែនជម្រកសត្វព្រៃកែវសីមា។
- ចំនួនសត្វព្រៃសំខាន់ៗ ១០ប្រភេទ ក្នុងចំណោម ១៣ ប្រភេទ មានស្ថានភាពកាន់តែប្រសើរ បើធៀបនឹងសេណារីយ៉ូដែលបានព្យាករណ៍ក្នុងការអនុវត្តគម្រោងរេដបូក ហើយប្រភេទសត្វសំខាន់ៗទាំង១៣ប្រភេទមានភាពប្រសើរ បើធៀបនឹងសេណារីយ៉ូដែលមិនមានគម្រោងរេដបូក។ លទ្ធផលបានបង្ហាញពីផលប៉ះពាល់ជាវិជ្ជមាននៃគម្រោងរេដបូកដែនជម្រកសត្វព្រៃកែវសីមាដែលជាតំបន់ជីវចម្រុះមានតម្លៃខ្ពស់។

PRE-VERIFICATION DRAFT

- លទ្ធផលទាំងនេះបង្ហាញពីជោគជ័យទាំងពីរបែបទាំងក្នុងការអភិរក្ស និងការការពារ នៅក្នុងដែនជម្រកសត្វព្រៃកែវសីមា ព្រមទាំងតំបន់ការពារធម្មជាតិសំខាន់ៗផ្សេងទៀតដែលត្រូវការកែលម្អជាបន្ទាន់ដើម្បីឆ្លើយតបទៅនឹងគោលដៅនៃការថែរក្សាចំនួនសត្វព្រៃ។ អត្រានៃការធ្លាក់ចុះចំនួនសត្វព្រៃនៅក្នុងដែនជម្រកសត្វព្រៃកែវសីមាគឺមានភាពយឺតជាង តំបន់នៅក្រៅតំបន់ការពារធម្មជាតិ។ តែទោះជាយ៉ាងណាយើងត្រូវបង្កើនកិច្ចខិតខំប្រឹងប្រែងការពារ និងអភិរក្សដើម្បីការពារប្រភេទសត្វក្រចកជំពាមធំៗដែលបានបាត់បង់ និងដើម្បីទប់ស្កាត់ការថយចុះនៃពពួកសត្វឈ្លូសផងដែរ។

*តារាងទី ៣ និន្នាការនៃចំនួនសត្វព្រៃដែលត្រូវបានព្យាករណ៍ និងចំនួនជាក់ស្តែងទៅតាមពូជសត្វសំខាន់ៗមួយចំនួននៅក្នុងដែនជម្រកសត្វព្រៃកែវសីមា*

| ឈ្មោះជាភាសាខ្មែរ | ឈ្មោះវិទ្យាសាស្ត្រ | ការព្យាករណ៍សេណារីដែលមិនមានវត្តមានគម្រោង | ស្ថានភាពប្រភេទសត្វជាក់ស្តែង (២០២០) | ចំនួនសត្វជាក់ស្តែង (២០១០) | ចំនួនសត្វជាក់ស្តែង (២០២០) |
|---|---|---|---|---|---|
| ស្វាកន្ទុយស | *Pygathrix nigripes* | ថយចុះ | ថេរ | 24,289 | 24,929 |
| ទោចថ្ពាល់លឿង | *Nomascus gabriellae* | ថយចុះ | ថេរ | 952 | 1432 |
| ស្វាព្រាម | *Trachypithecus germaini* | ថយចុះ | ថេរ | 2912 | 1487 |
| ស្វាក្តាម | *Macaca fascicularis* | ថយចុះ | ថេរ | 3125 | 1566 |
| ស្វាត្រោស | *Macaca leonina* | ថយចុះ | កើនឡើង | 2008 | 3929 |
| ស្វាអង្កត់ | *Macaca arctoides* | ថយចុះ | ថយចុះ | 529 | 230 |
| ក្ងោក | *Pavo muticus* | ថយចុះ | កើនឡើង | 309 | 745 |
| ជ្រូកព្រៃ | *Sus scrofa* | ថយចុះ | ថយចុះ | 3377 | 1100 |
| ឈ្លូស | *Muntiacus vaginalis* | ថយចុះ | ថយចុះ | 3383 | 825 |
| ទន្សោង | *Bos javanicus* | ថយចុះ | ថយចុះយឺត | 382 | - |
| ខ្ទីង | *Bos gaurus* | ថយចុះ | ថយចុះយឺត | 497 | 33 |
| រមាំង | *Rucervus eldii* | ថយចុះ | ថយចុះថយចុះយឺត | - | - |
| ប្រើស | *Rusa unicolor* | ថយចុះ | ថយចុះយឺត | - | - |

PRE-VERIFICATION DRAFT




*រូបភាពទី៣៖ ការប៉ាន់ប្រមាណចំនួនសត្វសំខាន់ៗនៅដែនជម្រកសត្វព្រៃកែវសីមា ផ្នែក(a)បង្ហាញពីវត្តមានសត្វព្រៃ ដែលនៅថេរ ឬកើនឡើង (b) បង្ហាញវត្តសត្វព្រៃដែលធ្លាក់ចុះ*

# ឧបសម្ព័ន្ធ ១

*តារាងទី ៤ ស្ថាប័នផ្សេងៗទៀតដែលពាក់ព័ន្ធនឹងគម្រោង*

| ឈ្មោះស្ថាប័ន | តួនាទីក្នុងគម្រោង | អ្នកទំនាក់ទំនង | តួនាទី | អាស័យដ្ឋាន |
|---|---|---|---|---|
| អង្គការសមាគមអភិរក្សសត្វព្រៃ (WCS) | ដៃគូដឹកនាំផ្នែកបច្ចេកទេស | លោក កែន សិរីរដ្ឋា | នាយកប្រចាំប្រទេស | ផ្ទះលេខ ២១ ផ្លូវលេខ ២១ សង្កាត់ទន្លេបាសាក់ រាជធានីភ្នំពេញ<br>ប្រអប់សំបុត្រលេខ WCS PO Box 1620 រាជធានីភ្នំពេញ កម្ពុជា |
| អង្គការក្រុមអភិវឌ្ឍជនបទកម្ពុជា (CRDT) | ការងារបង្កើតមុខរបរ និងការងារអភិវឌ្ឍសហគមន៍ | លោក ឱ ចន្ទី | នាយកប្រតិបត្តិ | ផ្ទះលេខ៦៩២ ផ្លូវលេខ២ ទីរួមខេត្តក្រចេះ<br>ប្រអប់សំបុត្រលេខ២៥៣៩ ភ្នំពេញ កម្ពុជា |
| មជ្ឈមណ្ឌល សំ វាសនា (SVC) | អេកូទេសចរណ៍ | លោក កុក កៅ | នាយក | ផ្ទះលេខ ០៥៥២ ក្រុមទី១២ វត្តបូណ៌ ទីរួមខេត្តសៀមរាប<br>ប្រអប់សំបុត្រលេខ ៩៣០៤៥ កម្ពុជា |
| Elephant Livelihood Initiative Environment (ELIE) | អេកូទេសចរណ៍ ការងារបង្កើតមុខរបរ និងការងារអភិវឌ្ឍសហគមន៍ | Ms. Jemma Bullock | ប្រធានគម្រោង | ផ្ទះអង្គការ ELIE នៅភូមិស្វាយចេក ឃុំសុខដុម សែនមនោរម្យ ខេត្តមណ្ឌលគិរី កម្ពុជា |
| អង្គការក្តីសង្ឃឹមពិភពលោកអន្តរជាតិ (WHI) | ការងារបង្កើតមុខរបរ និងការងារអភិវឌ្ឍសហគមន៍ | Dr. Emelita Goddard | នាយកប្រចាំប្រទេស | ផ្ទះលេខ៣ ផ្លូវលេខ៤២២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ កម្ពុជា 120101 |
| Regional Community Forestry Training Center for Asia and the Pacific (RECOFTC) | សហគមន៍តំបន់ការពារធម្មជាតិ និងការបង្កើតមុខរបរក្នុងសហគមន៍ | លោកស្រី ហ៊ូ កល្យាណ | នាយកកម្មវិធីប្រចាំប្រទេស | រដ្ឋបាលព្រៃឈើ អគារលេខ៤០ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាល២ ខណ្ឌដូនពេញ ភ្នំពេញ កម្ពុជា |
| Ibis Rice Conservation Co., Ltd | ផ្តល់ការលើកទឹកចិត្តទៅលើតម្លៃទីផ្សារចំពោះការអនុវត្តតាមគោលការណ៍អភិរក្ស | Nick Spencer | CEO | ផ្ទះលេខ៧ ផ្លូវលេខ ៥០៤ ភ្នំពេញ កម្ពុជា |
| អង្គការ សន្សំម្លប់ព្រៃ (SMP) | ជួយលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ និងគាំទ្រដល់ការងារអភិរក្សតាមរយៈរបរកសិកម្ម | កែវ សុជាតិ | នាយកប្រតិបត្តិ | ផ្ទះលេខ៧ ផ្លូវលេខ ៥០៤ ភ្នំពេញ កម្ពុជា |

PRE-VERIFICATION DRAFT

# ឧបសម្ព័ន្ធ ២

*តារាងទី ៥ ការសង្ខេបស្តីពីផលប្រយោជន៍គម្រោងរេដបូកកែវសីមា*

| លទ្ធផលគម្រោង | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលតាមដានគម្រោង | ផ្នែកនៃឯកសាយោង | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលអនុវត្តគម្រោងទាំងមូល |
|---|---|---|---|
| ចំនួននៃការចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចជាផ្លូវការនៅក្នុងតំបន់គម្រោង | ចំនួននៃការចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចចំនួន ៨ ស្ថិតនៅក្នុងដំណើរការ | 2 | សហគមន៍ជនជាតិដើមភាគតិចចំនួន ៧ នៃសហគមន៍ទាំង ១៥ ទទួលបានប័ណ្ណកម្មសិទ្ធិ |
| ចំនួនសហគមន៍ដែលទទួលស្គាល់ដោយក្រសួងបរិស្ថាន ក្នុងការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ នៅក្នុងតំបន់គម្រោង | សហគមន៍តំបន់ការពារធម្មជាតិចំនួន ២ បានទទួលស្គាល់ពីក្រសួងបរិស្ថាន និងសហគមន៍ចំនួន ៤ទៀតកំពុងស្ថិតក្នុងដំណើរការ | 2 | ចំនួន ៣ សហគមន៍តំបន់ការពារធម្មជាតិ បានទទួលស្គាល់ពីក្រសួងបរិស្ថាន ក្នុងការគ្រប់គ្រង |

*តារាងទី ៦ តារាងវង្វាស់ស្តង់ដារស្តីពីផលប្រយោជន៍គម្រោងរេដបូកកែវសីមា*

| ប្រភេទចំណាត់ថ្នាក់ | រង្វាស់ | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលតាមដានគម្រោង | ផ្នែកនៃឯកសាយោង | សមិទ្ធិផលសម្រេចបានក្នុង កំឡុងពេលអនុវត្តគម្រោងទាំងមូល |
|---|---|---|---|---|
| ការកាត់បន្ថយការ បំភាយ និងស្រូប យកចេញឧស្ម័ន | ការកាត់បន្ថយការបំភាយឧស្ម័នដែលបានប៉ាន់ស្មាននៅក្នុងតំបន់គម្រោងដែលវាស់វែងជាមួយសេណារីយ៉ូដែលគ្មានវត្តមានគម្រោង | 4,784,566 | 3.2 | 21,171,578 |
| គម្របព្រៃឈើ[1] | សម្រាប់គម្រោងរេដបូក[2]: ចំនួនហិកតានៃការកាត់បន្ថយនូវបាត់បង់ព្រៃឈើនៅក្នុងតំបន់គម្រោងត្រូវបានវាស់វែងដោយធៀបទៅនឹងសេណារីយ៉ូដែលគ្មានគម្រោង | 6,043 | | 25,204 |

[1] ដីធ្លីជាមួយបន្លែដុះដាលនូវរុក្ខជាតិ ដែលមាននិយមន័យទទួលស្គាល់ជាអន្តរជាតិ (ដូចជា UNFCCC, FAO ឬ IPCC) នៃអ្វីដែលបង្កើតជាព្រៃដែលរួមបញ្ចូលប៉ារ៉ាម៉ែត្រដែលមានកំរិតដូចជា ព្រៃឈើអប្បបរមាកម្ពស់ដើមឈើនិងកម្រិតនៃគម្របកន្សោមស្លឹក ហើយអាចរួមបញ្ចូលទាំងព្រៃចាស់ៗ ព្រៃដុះលូតលាស់ឡើងវិញ ព្រៃរេចរិលនិងព្រៃតំបន់ដីសើម (និយមន័យកម្មវិធី VCS) ។

[2] កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ចេញពីការបាត់បង់ព្រៃឈើនិងរិចរិលព្រៃឈើ (REDD): សកម្មភាពដែលកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ (GHG) ដោយកាត់បន្ថយឬបញ្ឈប់ការបំលែង ពីដីព្រៃឈើទៅជាដីដែលមិនមែនជាព្រៃឈើឬកាត់បន្ថយការរិចរិលនៃដីព្រៃដែលជីវម៉ាស់ព្រៃឈើត្រូវបានបាត់បង់ (និយមន័យកម្មវិធី VCS) ។

| ប្រភេទចំណាត់ថ្នាក់ | រង្វាស់ | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលតាមដានគម្រោង | ផ្នែកនៃឯកសាយោង | សមិទ្ធិផលសម្រេចបានក្នុង កំឡុងពេលអនុវត្តគម្រោងទាំងមូល |
|---|---|---|---|---|
| ការបណ្តុះបណ្តាល | ចំនួនសមាជិកសហគមន៍សរុបដែលបានបង្កើនជំនាញនិង / ឬចំណេះដឹងដែលជាលទ្ធផលនៃការបណ្តុះបណ្តាលដែលបានផ្តល់ដែលជាផ្នែកមួយនៃសកម្មភាពគម្រោង | 3,226 | 2 | 7,907 |
| | ចំនួនសមាជិកសហគមន៍ដែលជាស្ត្រីបានបង្កើនជំនាញនិង / ឬចំណេះដឹងដែលជាលទ្ធផលនៃការបណ្តុះបណ្តាលដែលបានផ្តល់ជាផ្នែកមួយនៃសកម្មភាពគម្រោង | 1,660 | 2 | 3,985 |
| ការងារ | ចំនួនសរុបនៃមនុស្សដែលបានធ្វើការក្នុងសកម្មភាពគម្រោង[3] ដែលសំដៅទៅលើចំនួនបុគ្គលិកពេញម៉ោង[4] | 596 | 2 | 2,220 |
| | ចំនួនស្ត្រីដែលបានធ្វើការក្នុងសកម្មភាពគម្រោង ដែលសំដៅទៅលើចំនួនបុគ្គលិកពេញម៉ោង | 68 | 2 | 236 |
| ការបង្កើនជីវភាព | ចំនួនប្រជាពលរដ្ឋសរុបដែលមានជីវភាព [5] ប្រសើរជាងមុនឬចំណូលដែលបានមកពីសកម្មភាពគម្រោង | 11,799 | 2, 4 | 11,799 |
| | ចំនួនស្ត្រីដែលមានជីវភាពប្រសើរឡើងឬទទួលបានប្រាក់ចំណូលដែលបានមកពីការធ្វើសកម្មភាពរបស់គម្រោង | 5,372 | 2, 4 | 5,372 |

PRE-VERIFICATION DRAFT

[3] ការងារនៅក្នុងសកម្មភាពគម្រោងមានន័យថាជាអ្នកធ្វើការងារដោយផ្ទាល់លើសកម្មភាពរបស់គម្រោងដើម្បីទទួលបានប្រាក់សំណង (ហិរញ្ញវត្ថុ ឬ អ្វីៗផ្សេងទៀត) រួមទាំងបុគ្គលិក បុគ្គលិកដែលជាប់កិច្ចសន្យា កម្មករដែលបានចុះកិច្ចសន្យានិងសមាជិកសហគមន៍ដែលទទួលបានប្រាក់កម្រៃ ដើម្បីធ្វើការងារពាក់ព័ន្ធនឹងគម្រោង។

[4] ភាពសមមូលការងារពេញម៉ោងត្រូវបានគេគណនាជាចំនួនសរុបនៃម៉ោងធ្វើការ (ដោយបុគ្គលិកពេញម៉ោង ក្រៅម៉ោង បណ្តោះអាសន្ននិង / ឬតាមរដូវកាល) ដោយចែកដោយចំនួនម៉ោងធ្វើការមធ្យមនៅក្នុងការងារពេញម៉ោងនៅក្នុងប្រទេស និងតំបន់ឬតំបន់សេដ្ឋកិច្ច (អនុលោមទៅតាមប្រព័ន្ធគណនេយ្យរបស់អង្គការសហប្រជាជាតិ (1993) វគ្គ 17.14 [15.102] [17.28]) ។

[5] ជីវភាពរស់នៅគឺជាសមត្ថភាព ទ្រព្យសម្បត្តិ (រួមទាំងទ្រព្យសម្បត្តិនិងធនធានសង្គម) និងសកម្មភាពចាំបាច់សម្រាប់ការរស់ (Krantz, Lasse, 2001. *The Sustainable Livelihood Approach to Poverty Reduction*. SIDA) អត្ថប្រយោជន៍នៃការប្រកបមុខរបរអាចរាប់បញ្ចូលទាំងអត្ថប្រយោជន៍ដែលបានរាយការណ៍នៅក្នុងតារាងម៉ែត្រការងារនៃតារាងនេះ។

| ប្រភេទចំណាត់ថ្នាក់ | រង្វាស់ | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលតាមដានគម្រោង | ផ្នែកនៃឯកសាយោង | សមិទ្ធិផលសម្រេចបានក្នុង កំឡុងពេលអនុវត្តគម្រោងទាំងមូល |
|---|---|---|---|---|
| សុខភាព | ចំនួនប្រជាពលរដ្ឋដែលបានទទួលសេវាសុខភាពប្រសើរជាងមុនដោយសារសកម្មភាពរបស់គម្រោងដែលត្រូវបានវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | 2,242 | 2 | 2,242 |
| | ចំនួនស្ត្រីដែលបានទទួលសេវាសុខភាពប្រសើរជាងមុនដោយសារសកម្មភាពរបស់គម្រោងដែលត្រូវបានវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | 1,066 | 2 | 1,066 |
| ការអប់រំ | ចំនួនសរុបនៃមនុស្សដែលទទួលបានការអប់រំឬគុណភាពនៃការអប់រំត្រូវបានកែលម្អជាលទ្ធផលនៃសកម្មភាពគម្រោងដែលត្រូវបានវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | 662 | 4 | 662 |
| | ចំនួនស្ត្រីនិងក្មេងស្រីដែលទទួលបានការអប់រំឬគុណភាពអប់រំដែលត្រូវបានកែលម្អដោយសារលទ្ធផលនៃគម្រោងដែលត្រូវបានវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | 358 | 4 | 358 |
| ទឹក | ចំនួនមនុស្សសរុបដែលទទួលបានការបង្កើនគុណភាពទឹកនិង / ឬបង្កើនលទ្ធភាពទទួលបានទឹកបរិភោគជាលទ្ធផលនៃសកម្មភាពគម្រោងដែលត្រូវបានវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង។ | 2,268 | 4 | 2,268 |
| | ចំនួនស្ត្រីដែលទទួលបានការបង្កើនគុណភាពទឹកនិង / ឬបង្កើនលទ្ធភាពទទួលបានទឹកផឹកដែលជាលទ្ធផលនៃសកម្មភាពគម្រោងដែលវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | 1,066 | 4 | 1,066 |

PRE-VERIFICATION DRAFT

| ប្រភេទចំណាត់ថ្នាក់ | វង្វាស់ | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលតាមដានគម្រោង | ផ្នែកនៃឯកសាយោង | សមិទ្ធិផលសម្រេចបានក្នុង កំឡុងពេលអនុវត្តគម្រោងទាំងមូល |
|---|---|---|---|---|
| **សុខមាលភាព** | ចំនួនសមាជិកសហគមន៍សរុបដែលសុខុមាលភាព[6] ត្រូវបានកែលម្អដែលជាលទ្ធផលនៃសកម្មភាពរបស់គម្រោង | 22,051 | 4 | 22,051 |
| | ចំនួនស្ត្រីដែលសុខុមាលភាពរបស់ពួកគេត្រូវបានកែលម្អជាលទ្ធផលនៃសកម្មភាពរបស់គម្រោង | 10,462 | 4 | 10,462 |
| **ការអភិរក្សជីវៈចម្រុះ** | ការផ្លាស់ប្តូរចំនួនហិកតាដែលគ្រប់គ្រងបានល្អប្រសើរដោយគម្រោងសម្រាប់ការអភិរក្សជីវចំរុះ[7] ដែលវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | 187,983 ha | 5.1 | 187,983 ha |
| | ចំនួននៃប្រភេទសត្វដែលជិតផុតពូជឬងាយរងគ្រោះ[8] ដែលត្រូវបានទទួលផលប្រយោជន៍ពីការកាត់បន្ថយការគំរាមកំហែងដែលជាលទ្ធផលនៃសកម្មភាពគម្រោង [9] ដែលវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | CR: 13 EN: 27 | 5.1 | CR: 13 EN: 27 |

PRE-VERIFICATION DRAFT

[6] សុខុមាលភាពគឺជាបទពិសោធរបស់ប្រជាជនអំពីគុណភាពនៃជីវិតរបស់ពួកគេ។ ផលប្រយោជន៍ខាងសុខមាលភាពអាចរាប់បញ្ចូលផលប្រយោជន៍ដែលបានរាយការណ៍នៅក្នុងតារាងដទៃទៀតនៃតារាងនេះ (ឧ. ការបណ្តុះបណ្តាល ការងារ សុខាភាព អប់រំ ទឹកស្អាតជាដើម) ប៉ុន្តែក៏អាចរួមបញ្ចូលផលប្រយោជន៍ផ្សេងទៀតដូចជា ការផ្តល់សិទ្ធិអំណាចដល់ក្រុមសហគមន៍ ពង្រឹងសិទ្ធិស្របច្បាប់ទៅលើធនធាន, ការអភិរក្សការប្រើប្រាស់នូវតំបន់ដែលមានសំខាន់សម្រាប់វប្បធម៌ ។ល។

[7] ការអភិរក្សជីវចម្រុះនៅក្នុងបរិបទនេះមានន័យថាជាតំបន់ ដែលវិធានការគ្រប់គ្រងជាក់លាក់ត្រូវបានអនុវត្តជាផ្នែកមួយនៃសកម្មភាពគម្រោងដែលមានគោលបំណងលើកកំពស់ការអភិរក្សជីវចម្រុះ។

[8] យោងទៅតាមបញ្ជីក្រហម IUCN នៃប្រភេទដែលត្រូវបានគំរាមកំហែងដោយ ។

[9] ដោយមិនមានវត្តមាននូវការវាស់វែងនូវចំនួន និងវត្តមានរបស់ប្រភេទ រាល់ការវាស់វែងនូវ ការកាត់បន្ថយការគំរាមកំហែងត្រូវបានគេប្រើជាភស្តុតាងនៃផលប្រយោជន៍សម្រាប់ការអភិរក្ស។